**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
ខុទ្ទកាល័យ
ចូល
លេខ 4030
ថ្ងៃទី 29.08.24 ម៉ោង
ហត្ថលេខា

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**នាយកដ្ឋានសវនកម្មផ្ទៃក្នុង**

លេខ......១៤១...ន.សផក

ថ្ងៃអង្គារ ៨រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**<u>កម្មវត្ថុ:</u>** អំពីរបាយការណ៍សវនកម្មនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ស្ពឺ

**<u>យោង:</u>**
- សេចក្តីជូនដំណឹងលេខ១២០ ដនស/នា.សផក ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ ស្តីពីការអនុវត្តផែនការសវនកម្ម និងផែនការតាមដានអនុសាសន៍ប្រចាំឆ្នាំ២០២៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតបញ្ជាបេសកកម្មលេខ០៧៩ ដនស ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៤របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតបញ្ជាបេសកកម្មលេខ០៩០ ដនស ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២៤ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមអនុញ្ញាតគោរពជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា របាយការណ៍សវនកម្មផ្ទៃក្នុងនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ស្ពឺ ជារបាយការណ៍អនុវត្តតាមគំរូស្តង់ដារបាយការណ៍សវនកម្ម របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឱ្យគ្រប់ក្រសួង-ស្ថាប័នអនុវត្តតាម ហើយរបាយការណ៍នេះក៏នឹងត្រូវផ្ញើជូន អាជ្ញាធរសវនកម្មជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ។

ឆ្លងតាមការធ្វើសវនកម្មបានបង្ហាញឱ្យឃើញថា ការគ្រប់គ្រង និងប្រើប្រាស់ថវិកា មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ស្ពឺ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២៣ មានចំណុចល្អមួយចំនួនដូចជា÷

- កិច្ចបញ្ជិកា ការរៀបចំរក្សាឯកសារគណនេយ្យ ឯកសាររណប និងការកត់ត្រាមានសណ្តាប់ធ្នាប់ល្អជាងឆ្នាំកន្លងមក។
- ការអនុវត្តតាមអនុសាសន៍ដែលប្រតិភូសវនកម្មផ្ទៃក្នុងបានផ្តល់ជូនសម្រាប់ការិយបរិច្ឆេទកន្លងមកបានល្អប្រសើរ។

ទន្ទឹមនឹងនោះ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ស្ពឺ ក៏នៅមានចំណុចខ្វះខាតមួយចំនួនដូចជា÷

**១-ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ**

-មន្ទីរមិនទាន់បានបិទលេខកូដសម្គាល់លើសម្ភារការិយាល័យ បរិក្ខារបច្ចេកទេស និងគ្រឿងសង្ហារិម។

**២-ការងារសុរិយោដី និងការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ(GIS)**

-បន្ទប់ដាក់ម៉ាស៊ីនមេ (Server) ពុំមានបំពាក់ប្រព័ន្ធការពារអគ្គីភ័យ។

-បន្ទប់ទុកដាក់រក្សាឯកសារសុរិយោដី ពុំមានបំពាក់ប្រព័ន្ធការពារអគ្គីភ័យ និងកង្ហារបឺតខ្យល់។

**៣-ការងារសុរិយោដី និងភូមិសាស្ត្រ និងកម្មវិធីអនុវិស័យរដ្ឋបាលដីធ្លី**

-មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ស្ពឺ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលខូចចាប់ពីឆ្នាំ២០១៨ រហូតដល់បច្ចុប្បន្ន ចំនួន **១០,៩៧២** សន្លឹក។

**៤-ការអនុវត្តការងារសំណង់**

-ការផ្តល់លិខិតអនុញ្ញាតសាងសង់មានចំនួន ២០ គម្រោង ប៉ុន្តែបានផ្តល់លិខិតអនុញ្ញាតបើកការដ្ឋានបានតែចំនួន ០៥ គម្រោង និងលិខិតអនុញ្ញាតបិទការដ្ឋានចំនួន ០១ គម្រោង។

-ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក ស្ទើរតែទាំងអស់ (លើកលែងតែការិយាល័យ.ដ.ន.ស.ភក្រុងច្បារមន) មិនបានបញ្ជូននូវសំណុំឯកសារលិខិតអនុញ្ញាតសាងសង់សំណង់ ដែលម្ចាស់សំណង់បានសុំការអនុញ្ញាតរួចរាល់ មកការិយាល័យសំណង់របស់មន្ទីរ។

-ពុំមានទិន្នន័យលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់។

**ប្រតិភូសវនកម្មបានផ្តល់អនុសាសន៍កែលម្អដូចខាងក្រោម÷**

១-មន្ទីរត្រូវបិទលេខកូដសម្គាល់លើសម្ភារការិយាល័យ បរិក្ខារបច្ចេកទេស និងគ្រឿងសង្ហារិមទាំងអស់ ឱ្យបានរួចរាល់។

២-មន្ទីរត្រូវបំពាក់ប្រព័ន្ធការពារអគ្គីភ័យនៅក្នុងបន្ទប់ម៉ាស៊ីនមេ(Server)។ បន្ទប់ទុកដាក់រក្សាឯកសារសុរិយោដីក៏ត្រូវបំពាក់ប្រព័ន្ធការពារអគ្គីភ័យ និងកង្ហារបឺតខ្យល់ជាបន្ទាន់។

៣-មន្ទីរត្រូវធ្វើបច្ចុប្បន្នភាពសន្លឹកបណ្ណខូច រួចហើយស្នើសុំបង្កើតគណៈកម្មការត្រួតពិនិត្យសន្លឹកបណ្ណខូច និងបូកសរុប ដើម្បីដុតកម្ទេច ស្របតាមលិខិតលេខ៣២៩ អ/សជភ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងសន្លឹកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ។

៤-ចំពោះការងារសំណង់ មន្ទីរត្រូវ៖

- ខិតខំជំរុញការផ្សព្វផ្សាយណែនាំឱ្យម្ចាស់សំណង់ មកស្នើសុំលិខិតអនុញ្ញាតសាងសង់ និងលិខិតអនុញ្ញាតបើកការដ្ឋាន មុននឹងធ្វើការសាងសង់ ព្រមទាំងស្នើសុំលិខិតអនុញ្ញាតបិទការដ្ឋាន(វិញ្ញាបនបត្រប្រើប្រាស់សំណង់)ក្រោយបញ្ចប់ការសាងសង់។
- ជំរុញការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង-ស្រុក បញ្ជូននូវសំណុំឯកសារលិខិតអនុញ្ញាតសាងសង់សំណង់ នៅពេលដែលម្ចាស់សំណង់បានសុំការអនុញ្ញាតរួចរាល់ មកការិយាល័យសំណង់របស់មន្ទីរ។
- ណែនាំក្រុមជាងសំណង់ ឱ្យមកស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មក្រុមជាងសំណង់ មុនពេលដំណើរការអាជីវកម្ម ស្របតាមសារាចរណែនាំស្តីពីការគ្រប់គ្រងក្រុមជាងសំណង់លេខ០០១ ដនស/អ.ស.ណ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាប និងមានមតិដឹកនាំ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពពីខ្ញុំបាទ។

**ប្រធាននាយកដ្ឋាន**

**យួន-សុជាតិ**

| **មតិឯកឧត្តមរដ្ឋលេខាធិការប្រចាំការ** | **មតិឯកឧត្តមប្រធានក្រុមការងារ** |
|---|---|
| | |

28. 08 24

**មតិសម្រេចឯកឧត្តមឧបនាយករដ្ឋមន្ត្រី**